ព្រះរាជាណាចក្រកម្ពុជា -139-

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ សើរើ

លេខ : ០៣សរ

ចុះថ្ងៃទី០៣ .០៩ ២០០២

សាលដីកា

លេខ: ១៦

ចុះថ្ងៃទី៣០ .០៤ ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះរួមក្រុមជាសាធារណៈនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក ទៀវ មួន ចៅក្រម

៤ - លោក ជីវ កេង ចៅក្រម

៥ - លោក ប្រាក់ គឹមសាន ចៅក្រម

៦ - លោក ស៊ិន ឌឹម ចៅក្រម

៧ - លោក ប៉ែន សាវឿន ចៅក្រមរាយការណ៍

៨ - លោក យស់ សូខឿន ចៅក្រម

៩ - លោក សោម សិរិវុឌ្ឍ ចៅក្រម

ក្រឡាបញ្ជី

លោក ឃាង ស្រ៊ុន

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសើរើរបស់ទណ្ឌិតហេង ចិន្តា ចុះថ្ងៃទី២៧ .០៨ ២០០២ តវ៉ាពីសាលក្រមព្រហ្មទណ្ឌាពរលេខ១៧ "ង" ចុះថ្ងៃទី០១ .០៤ ២០០២របស់តុលាការក្រុងភ្នំពេញ និងសំណុំរឿងព្រហ្មទណ្ឌសើរើលេខ ០៣សរ ចុះថ្ងៃទី០៣ .០៩ ២០០២ របស់តុលាការកំពូល ។

- ទណ្ឌិតឈ្មោះ ហេង ចិន្តា "ម្ចាស់បណ្តឹងសើរើ" ភេទ ស្រី អាយុ ៥១ ឆ្នាំ កើតនៅ សង្កាត់ បឹងសាឡាង ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ១ ៧៥អឺ០ សង្កាត់ មនោរម្យ ខណ្ឌ ៧ មករា ក្រុងភ្នំពេញ សាសនា ព្រះពុទ្ធ មុខរបរលក់ទឹកក្រឡុក ប្តីឈ្មោះចាន់ បូរី ។ ឪពុកឈ្មោះជា អេងយូ "ទ" ម្តាយឈ្មោះ អៀប មួយ "រ" ។ ទោសពីមុនគ្មាន ។

- មេធាវី គ្មាន

- ត្រូវចោទពីបទ បង្ករបួសស្នាម ប្រព្រឹត្តនៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី២៣ .០៧ - ២០០១

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ុន សុវណ្ណដារ៉ែត ភេទស្រី អាយុ ១៨ ឆ្នាំ នៅ សង្កាត់ មនោរម្យ ខណ្ឌ ៧ មករា ។

......២ ....

- តាមរបាយការណ៍របស់នគរបាល ខណ្ឌ៧មករា ចុះថ្ងៃទី៤ ០៧ ២០០១ បាន បញ្ជាក់ថា ៖ កាលពីថ្ងៃទី២៣ ៦ ២០០១ វេលាម៉ោង១៩និង៤៥នាទី មានការវាយគ្នានៅមុខ ផ្ទះលេខ៧៧អឺ០ សង្កាត់មនោរម្យ រវាងឈ្មោះ ហេង ចិន្តា និងស៊ិន សុវណ្ណដារ៉ែត ដោយនៅពេល នោះឈ្មោះស៊ិន សុវណ្ណដារ៉ែត បានដាក់ស៊ុយទុកលើដំបូលឡូ ឡូវលើ ពេលខ្យល់បក់មកក៏បុំងបុយនោះ ធ្លាក់ដល់មុខផ្ទះហេង ចិន្តា ។ ប្ដីរបស់ឈ្មោះហេង ចិន្តា បានទើសលព្រោះដាលពីរយទៀត ទើប ស៊ិន សុវណ្ណដារ៉ែត ក៏បានទៅរុំបុយនោះវិញ ពេលនោះក៏មានការជជែកនិងវាយតប់គ្នាតែម្ដង ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់អយ្យការអមតុលាការក្រុងភ្នំពេញថា ឈ្មោះ ហេង ចិន្តា ហៅម៉ាប់ ភេទស្រី អាយុ ៥២ ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើបង្ករបួសស្នាមលើជន រងគ្រោះឈ្មោះ ស៊ិន សុវណ្ណដារ៉ែត មែន នៅក្រុងភ្នំពេញកាលពីថ្ងៃទី ២៣ - ៦ - ២០០១ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៧ "ង" ចុះថ្ងៃទី០១ ០៤ ២០០២ របស់ តុលាការក្រុងភ្នំពេញ ដែលមានសេចក្ដីសំរេចដូចតទៅ ៖

១ - ផ្ដន្ទាទោសលើឈ្មោះ ហេង ចិន្តា ហៅម៉ាប់ ភេទស្រី អាយុ ៥១ ឆ្នាំ កើត នៅបឹងសាឡាង ក្រុងភ្នំពេញ ដាក់ពន្ធនាគារកំណត់រយៈពេល០៣ ខែ តែទោសនេះត្រូវព្យួរ ទាំងស្រុង ក្នុងកំរិតសាកល្បង០៥ ឆ្នាំ ចាប់គិតពីថ្ងៃប្រកាសសាលក្រមតទៅ ។

ពីបទ ៖ បង្ករបួសស្នាម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៣ ៦ ២០០១ តាម បញ្ញត្តិមាត្រាទី៤១ ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - បង្គាប់អោយឈ្មោះ ហេង ចិន្តា ហៅម៉ាប់ ធ្វើការជួសជុលសំណងខូចខាតផ្លូវ កាយនិងផ្លូវចិត្តជាប្រាក់សរុបចំនួន ពីរលានរៀលអោយទៅជនរងគ្រោះឈ្មោះស៊ិន សុវណ្ណដារ៉ែត ចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ ។ រីឯសំណូមពរលើសពីនេះត្រូវបដិសេធចោល ។

ក្នុងករណីដែលឈ្មោះ ហេង ចិន្តា ហៅម៉ាប់ គ្មានទ្រព្យសម្បត្តិនិងប្រាក់ ដើម្បី សងធនទណ្ឌ ដូចបានកំណត់ក្នុងប្រការខាងលើនេះ ត្រូវចាប់ដាក់គុកបង្ខំដល់រូបកាយដើម្បីទារប្រាក់ ធនទណ្ឌ ដោយអនុវត្តតាមច្បាប់ស្ដីពីវិធីអនុវត្តការចាប់ដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

- បានឃើញបណ្ដឹងសើរើរបស់ទណ្ឌិតឈ្មោះ ហេង ចិន្តា ហៅម៉ាប់ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០២ ដោយមានភ្ជាប់មកនូវភស្តុតាងថ្មីបន្ថែមចំនួន ០២ ច្បាប់មកតុលាការកំពូល គឺ ៖ ១ - សំបុត្រកំណើត ២ - បណ្ណគ្រួសារ ។

- បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអគ្គអយ្យការនាពេលសវនាការថា ៖ មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ៖ ឈ្មោះ ហេង ចិន្តា ពិតជាបានចិញ្ចឹមបីបាច់ថែរក្សាឈ្មោះ នាង ចាន់សុភាព ហៅស៊ិន សុវណ្ណដារ៉ែត ជាកូនពិតប្រាកដមែន ការដែលនគរបាលខណ្ឌ៧មករា ប្រគល់ ឈ្មោះចាន់ សុភាព ឱ្យទៅឈ្មោះម៉ុន គ្រប់គ្រងនិងប្ដូរឈ្មោះស៊ិន សុវណ្ណដារ៉ែត វិញនោះជាការ ពុំត្រឹមត្រូវតាមច្បាប់ទេឡើយ ។

- តំកល់ពាក្យបណ្ដឹងសើរើចុះថ្ងៃទី២៧ - ០៨ ២០០២ របស់ទណ្ឌិតឈ្មោះហេង ចិន្តា

ទុកជាបានការពេញទាំងមូល ។

- បានស្ដាប់ចម្លើយទណ្ឌិតឈ្មោះ ទេង ចិន្តា អះអាងនៅពេលសវនាការថាៈ ខ្លួនពិតជាបានចិញ្ចឹមកូនឈ្មោះ ចាន់ សុភាព និងមានឈ្មោះសព្វថ្ងៃនេះថា ស៊ិន សុវណ្ណដារ៉ែណេត នេះពិតប្រាកដ ។

-មានលិខិតផ្ញើ "ផ្ទាល់ស្ដី" បញ្ជាក់ត្រឹមត្រូវ

-ការចិញ្ចឹមតាំងពីបានជើងក្រហមមករហូតដល់ពេញវ័យ ទើបមានអ្នកយកទៅចិញ្ចឹមដោយលួចលាក់ ។

-ការខាតមួយនេះដោយអៀនពេក ព្រោះនាងនោះបានជេរប្រមាថឪពុក ម្ដាយថាៈអាភ្លើ មីភ្លើ "ទើបខ្ញុំអត់ទ្រាំពុំបានក៏ដាក់បួយកំភ្លៀងមិនធ្ងន់ធ្ងរទេ ស្រាលប៉ុណ្ណោះ ។

-សូមជួយរកយុត្តិធម៌ដល់នាងខ្ញុំផង ។

- បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការថាៈ សូមរក្សាការសន្និដ្ឋានរបស់ខ្លួនទុកនៅដដែល ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ .
- ក្រោយពីបានស្ដាប់ចម្លើយរបស់ម្ចាស់បណ្ដឹងសើរើ .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសើរើ ចុះថ្ងៃទី ២៧-០៨-២០០២ របស់ឈ្មោះ ទេង ចិន្តាដែលប្ដឹងសុំសើរើពីសាលក្រមព្រហ្មទណ្ឌលេខ ១៧ "ង" ចុះថ្ងៃទី ០១-០៤-២០០២ របស់តុលាការក្រុងភ្នំពេញ ធ្វើឡើងត្រឹមត្រូវតាមមាត្រា ២២៧ នៃ ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ និង មាត្រា ១៥ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញ ក្រោយពេលសាលក្រមចូលជាស្ថាពរ ទណ្ឌិតបានប្ដឹងសុំសើរើរឿងក្ដីមកតុលាការកំពូល តាមបណ្ដឹងចុះថ្ងៃទី ២៧-០៨-២០០២ ដោយបាននាំមកនូវភស្ដុតាងថ្មី ជូនមកតុលាការកំពូល គឺៈ

១- សំបុត្រកំណើតរបស់ឈ្មោះ ចាន់ សុភាព ទៅ ស៊ិន សុវណ្ណដារ៉ែណេត ជាឈ្មោះប្ដូរថ្មី

២- បណ្ណគ្រួសារដែលមានឈ្មោះ ចាន់ សុភាព ជាកូនក្នុងបន្ទុក .

៣- លិខិតឆ្លងដែនលេខ អិន០០៨០៦៣០ ឯកសារទាំងនេះ បញ្ជាក់ថាឈ្មោះចាន់សុភាព និង ឈ្មោះទេង ចិន្តា ពិតជាកូននិងម្ដាយប្រាកដមែន ដោយពុំទាន់មានសាលក្រមណាដកអំណាចមេបាទេ ហើយភស្ដុតាងទាំងនេះ ពេលជំនុំជំរះនៅតុលាការក្រុងភ្នំពេញពុំមាននៅឡើយ ដូច្នេះផ្អែកតាម គោលការណ៍មាត្រា ២៣០ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលគប្បីទទួលបណ្ដឹងសើរើនេះទុកជាត្រឹមត្រូវតាមច្បាប់ ។

ហេតុដូច្នេះ

...៥...

វិនិច្ឆ័យសេចក្ដីចំពោះមុខ បង្គាប់បណ្ដឹងសើរើ

១ - ទទួលបណ្ដឹងសើរើចុះថ្ងៃទី ២៧.០៨.២០០២ របស់ទណ្ឌិត សោង ចិន្តា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២ - ផ្អាកការអនុវត្តសាលក្រមព្រហ្មទណ្ឌលេខ ១៧ "ង" ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០២ របស់តុលាការក្រុងភ្នំពេញ ជាបណ្ដោះអាសន្ន ។

៣ - សាលដីកានេះប្រកាសតាមសវនាការជាសាធារណៈ នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៣ ។